# ជំរឿនវត្ថុបុរាណនៅក្បាលស្ពាន

ចាយ រចនា
អាជ្ញាធរអប្សរា

“ក្បាលស្ពាន” ជារមណីយដ្ឋានផងជាស្ថានីយ៍បុរាណផង។ ជារមណីយដ្ឋានដោយសារភូមិសាស្ត្រព្រមទាំងធម្មជាតិនៅទីនេះគួរជាទីត្រកាលក្រៃលែង។ ជាស្ថានីយ៍បុរាណត្បិតខ្មែរនៅស.វ.ទី១១ បានរៀបចំកន្លែងនេះឱ្យមានភាពសក្ការៈ មានការចារឹកអក្សរនិងឆ្លាក់ថ្មជាអាទិ៍។

បូជនីយដ្ឋាននេះស្ថិតនៅលើភ្នំទាបមួយ តាមបណ្ដោយអូរក្បាលស្ពានប្រមាណ២០០ម៉ែត្រ[១]។ អូរក្បាលស្ពានជាប្រភពទឹកសំខាន់មួយនៃស្ទឹងសៀមរាប។ រីឯប្រភពមួយទៀតគឺភ្នំក្រោល។ ភ្នំក្បាលស្ពាននិងភ្នំក្រោលស្ថិតនៅខាងលិចភ្នំគូលែន ហើយដាច់ចេញពីភ្នំនេះដោយជ្រលង “កណ្ដុរស” ដែលជាច្រកផ្លូវទៅកាន់ស្រែណូយនិងអន្លង់វែង។ បើពោលតាមទស្សនៈរដ្ឋបាល ក្បាលស្ពានចំណុះឱ្យភូមិខ្នាររង្វះ ឃុំឃុនរាម ស្រុកបន្ទាយស្រី ខេត្តសៀមរាប ហើយមានចម្ងាយប្រមាណ១៤គ.ម. ខាងឦសានប្រាសាទបន្ទាយស្រី។

## ១_ ការសិក្សាកន្លងមក

នៅចន្លោះខែមករាឆ្នាំ១៩៦៧និងខែមិថុនាឆ្នាំ១៩៧០ លោកJean Boulbet ព្រមទាំងលោកBruno Dagens បានធ្វើការស្រាវជ្រាវរុករកបេតិកភណ្ឌជំនាន់ផ្សេងៗដែលមាននៅតំបន់គូលែនទាំងមូល។ ការងារនេះមិនមែនថ្មីស្រឡាងទេ ព្រោះផ្អែកមូលដ្ឋានលើការស្រាវជ្រាវដែលមានពីមុននោះមកទៀត[២]។ ប៉ុន្តែទោះជាយ៉ាងណាក៏បញ្ជីបេតិកភណ្ឌរបស់លោកទាំងពីរនោះមានភាពទូលំទូលាយជាងគេ បើគិតមកទល់ពេលថ្មីៗនេះ[៣]។ ដោយសារការសិក្សានោះហើយ បានជានៅឆ្នាំ១៩៦៨ លោក Jean Boulbet បានជួបនិងលោកតា ទេព មី ជាអ្នកនាំផ្លូវគាត់ទៅដល់ក្បាលស្ពាន។ រហូតមកទល់ពេលនោះ អ្នកស្រាវជ្រាវពុំដែលស្គាល់បុរាណដ្ឋានដ៏ល្អនោះឡើយ មានតែអ្នកស្រុកតំបន់នោះផ្ទាល់ទើបស្គាល់ដឹងថាមានទីសក្ការៈកប់បាំងក្នុងព្រៃភ្នំ។ លោក Jean Boulbet បានឱ្យគេឆ្ការព្រៃអស់រយៈពេលបួនខែ ហើយធ្វើការចុះបញ្ជី ដោយបែងចែកទីដែលមានបុរាណវត្ថុទាំងនោះចេញជា១៥ តំបន់។ បញ្ជីវត្ថុនោះមានភ្ជាប់រូបថតមួយចំនួនជាមួយផង។ ក្នុងនោះមានសិលាចារឹក១០ផ្ទាំង ដែលក្រោយមកលោក Claude Jacques យកមកចុះលេខរៀងតពីបញ្ជីសិលាចារឹកដែលធ្លាប់មានមក[៤]។ មិនតែប៉ុណ្ណោះ សិលាចារឹកទាំងនោះត្រូវបានប្រែដោយអ្នកនិពន្ធខាងលើនេះ[៥]។

---

[១] រយៈទទឹង៖ ១៥១៣២៦៣ ខាងជើង។ រយៈបណ្ដោយ៖ ៤៨៣៩៣៥៤២ ខាងកើត។ រយៈកំពស់៖ ២០០ម ពីផ្ទៃទឹកសមុទ្រ។

[២] ឧទាហរណ៍៖ - Parmentier 1913: 1-64.
- Lunet de Lajonquière 1902: 303-304; 1912: 236.
- Stern 1938: 426 ff.

[៣] សូមអាន Boulbet et Dagens 1973.

[៤] Jacques 1971: 177-195.

[៥] Jacques 1999: 357-364.

២_ ការផ្ទៀងផ្ទាត់ឡើងវិញ

ជាអកុសល ជិតមួយទសវត្សកន្លងមកនេះ មានការដាប់ចម្លាក់ច្រើនកន្លែងនៅក្បាលស្ពាន។ អាជ្ញាធរអប្សរាក៏ចាត់វិធានការណ៍រៀបចំដាក់ថ្នាំយាមល្បាត ព្រមទាំងរៀបចំសម្រួលផ្លូវឱ្យអ្នកទស្សនាបានទៅដល់ងាយស្រួលផងដែរ។ គឺក្នុងបរិបទនេះហើយដែលខ្ញុំសម្រេចចិត្តធ្វើការសិក្សាផ្ទៀងផ្ទាត់ឡើងវិញតាមសភាពការណ៍ថ្មី ទៅដាក់ក្នុងគម្រោងនិក្ខេបបទបញ្ចប់ការសិក្សាមួយ[៦]។ ខ្ញុំពឹងផ្អែកទាំងស្រុងទៅលើផែនទីនៃលោក Boulbet។ រីឯលេខបញ្ជីដែលមានមកខ្ញុំក៏គោរពតាមទាំងស្រុង ដូច្នេះតំណែលបុរាណដែលកន្លងផុតលោក Boulbet ខ្ញុំបានចុះលេខបន្តបន្ទាប់មកទៀត។ ដើម្បីងាយស្រួលក្នុងការសិក្សា ខ្ញុំចែកបរិវេណបុរាណនៅក្បាលស្ពានជា៥ក្រុមធំៗ។ ប៉ុន្តែក្នុងការរៀបចំអត្ថបទនេះ ខ្ញុំធ្វើការកែលំអលើនិក្ខេបបទនោះខ្លះទៀត ដើម្បីឱ្យមានភាពសុក្រិតជាងមុន។ ក្នុងក្រុមនិមួយៗ ខ្ញុំចែកវត្ថុផ្សេងៗជា២ប្រភេទ ៖ ប្រភេទទី១ គឺចម្លាក់នៅច្រាំង, បាតស្ទឹង និងនៅលើថ្មដែលដុះផុតពីទឹក។ ប្រភេទទី២ គឺពើង។

ក_ វត្ថុប្រភេទទី១

នៅតាមបណ្តោយស្ទឹងមានចម្លាក់ច្រើនបែបយ៉ាង។ ក្នុងចំណោមនោះ មានចម្លាក់រូបលិង្គដែលអាចចែកចេញជា ៖ លិង្គរាយ, លិង្គបញ្ឈរ, លិង្គជាក្រុម, និងលិង្គទោល។ រីឯចម្លាក់ដែលមានរូបទេព គឺមាន១២ផ្ទាំង។ ភាគច្រើនជារូបព្រះឥសូរ, ព្រះនារាយណ៍, និងព្រះព្រហ្ម។ ក្នុងនោះមានព្រះឥសូរមួយផ្ទាំង, ព្រះនារាយណ៍ផ្ទុំលើនាគ៨ផ្ទាំង, ព្រះព្រហ្មមួយផ្ទាំង, និងចម្លាក់រូបទេព២ផ្ទាំង (លេខជំរឿនថ្មី៣៨, និង៣៩)។ មិនតែប៉ុណ្ណោះមានសិលាចារឹក៣ផ្ទាំងនៅលើផ្ទែក ដែលលូតផុតពីទឹក។

ខ_ វត្ថុប្រភេទទី២ ៖ ពើង

ពើងជារូងរាក់ឬជ្រៅ ដែលមានផ្ទាំងថ្មខាងលើលៀនចេញមកមុខហាក់បីដូចជាយ៉មួយ។ ទោះជាជម្រៅទៅក្នុងរាក់យ៉ាងណាក្តី ក៏ពើងផ្តល់ជាទីជម្រកមួយបាន។ នៅក្បាលស្ពានមានពើង៥ ដែលពីបុរាណមកគេរៀបចំជាកន្លែងបូជា ដោយសារឃើញមានសំណល់បុរាណជាប់ទីនោះ ដូចជាសិលាចារឹកនិងចម្លាក់ជាដើម។ ក្នុងចំណោមនោះ មានពើងមួយដែលគេចារអក្សរនៅលើ ជញ្ជាំងថ្មថាមានតម្កល់លិង្គព្រះឥសូរនៅទីនោះ។ មានពើងមួយទៀតដែលពុំឃើញមានវត្ថុដើមទេ ប៉ុន្តែដែលយើងយល់ថាខ្មែរបុរាណប្រើប្រាស់ជាទីបូជា (សូមមើលលេខជំរឿនថ្មី ២៨)។

៣_ អំពីសិលាចារឹក

សិលាចារឹក១០ផ្ទាំងត្រូវបានចុះបញ្ជីនិងធ្វើការសិក្សាដោយលោក Claude Jacques ដូចពោលពីលើមក។ ខ្ញុំបានប្រទះឃើញអក្សរថ្ម៥ផ្ទាំងផ្សេងទៀត ដែលកន្លងផុតអ្នកមុនៗ ដោយសារវិចរិលខ្លាំងពេក (សូមមើលលេខជំរឿនថ្មី ៦, ១០ក, ១០ខ, ១១ខ, និង២៧)។ ខ្ញុំពុំមានលទ្ធភាពបង់លេខផ្ទាល់ឱ្យសិលាចារឹកទាំង៥នេះទេ (K និង Ka) ព្រោះជាបន្ទុកស្ថាប័នជាតិ និងអន្តរជាតិ ដែលធ្លាប់បំពេញកិច្ចនេះរៀងមក។

សារុបមក បញ្ជីដែលខ្ញុំភ្ជាប់មកនេះជាលទ្ធផលនៃការពិនិត្យលំអិតលើការស្រាវជ្រាវដែលមានពីមុនមក ហើយដែលមានរាប់បញ្ចូលបេតិកភណ្ឌខ្លះដែលរំលងផុតអ្នកមុនៗ។ រាយមកមានចំនួន៤០។ រីឯវត្ថុនិមួយៗសុទ្ធសឹងមានការវាស់វែង បរិយាយទៅតាមក្បួនខ្នាតទំនើប។ អាជ្ញាធរអប្សរាទើបនឹងបានរៀបចំកាតាឡុកលំអិតនៃបុរាណវត្ថុនៅក្បាលស្ពានទាំងមូលជាស្ថាពរ។ សៀវភៅនេះនឹងចេញផ្សព្វផ្សាយជាកម្រិតតូច ក្នុងរង្វង់អ្នកស្រាវជ្រាវ ឬស្ថាប័នពាក់ព័ន្ធនិងកិច្ចការការពារបេតិកភណ្ឌ។ នៅទីនេះ ខ្ញុំស្រង់យករូបមួយចំនួនតូចនៃវត្ថុទាំង២ប្រភេទ ដែលបានពោលនៅលើមកបង្ហាញជាឧទាហរណ៍។

[៦] ចាយ រចនា ២០០២។


ក្បាលស្ពាន




ប្លង់បូជនីយដ្ឋានក្បាលស្ពាន, សម្រួលអំពីប្លង់របស់លោក Jean Boulbet

| លេខជំរឿនថ្មី | វត្ថុបុរាណ | លេខបញ្ជីចាស់ | ក្រុម |
|---|---|---|---|
| ១ | លិង្គរាយនៅបាតស្ទឹង | | I |
| ២ | បល្ល័ង្កឆ្លាក់ផ្ទាល់លើថ្មធម្មជាតិ | | I |
| ៣ | ចម្លាក់លើជញ្ជាំងថ្មធម្មជាតិ | 3 | I |
| ៤ | សត្វកង្កែប | 1 | I |
| ៥ | ព្រះនារាយណ៍ផ្ទំលើនាគ | | I |
| ៦ | សិលាចារឹកនៅជាប់តែឯង | | I |
| ៧ | អាងទឹកមានចម្លាក់ | 4 | I |
| ៧ក | ព្រះនារាយណ៍ផ្ទំលើនាគ | 4 | I |
| ៧ខ | ព្រះនារាយណ៍ផ្ទំលើនាគ | 4 | I |
| ៧គ | ចម្លាក់លើជញ្ជាំងអាងទឹក ខាងលិច | 4 | I |
| ៧ឃ | ចម្លាក់លើជញ្ជាំងអាងទឹក ខាងកើត | 4 | I |
| ៨ | អាងទឹកមានបល្ល័ង្កចំកណ្តាល | 5 | I |
| ៨ក | ព្រះនារាយណ៍ផ្ទំលើនាគ | 5 | I |
| ៨ខ | ព្រះនារាយណ៍ផ្ទំលើនាគ | 5 | I |
| ៩ | ពើងមានសិលាចារឹកនិងបំណែកវត្ថុ | | I |
| ៩ក | សិលាចារឹក | K1012,1° | I |
| ៩ខ | សិលាចារឹក | K1012,2° | I |
| ៩គ | សិលាចារឹក | K1012,3° | I |
| ៩ឃ | បំណែកបល្ល័ង្ក | | I |
| ១០ | ពើងមានសិលាចារឹកនិងបំណែកវត្ថុ | | I |
| ១០ក | សិលាចារឹក | | I |
| ១០ខ | សិលាចារឹក | | I |
| ១០គ | បំណែកបល្ល័ង្ក | | I |
| ១១ | ពើងមានសិលាចារឹកនិងបំណែកវត្ថុ | | I |
| ១១ក | សិលាចារឹក | K1016 | I |

| | | | |
|---|---|---|---|
| ១១ខ | សិលាចារឹក | | I |
| ១១គ | បល្ល័ង្ក | | I |
| ១១ឃ | បំណែកបល្ល័ង្ក | | I |
| ១១ង | បំណែកដងខ្លួនទេព | | I |
| ១២ | ពើងមានរូបចម្លាក់និងសិលាចារឹក | 6 | I |
| ១២ក | សិលាចារឹក | K1011,1⁰ | I |
| ១២ខ | សិលាចារឹក | K1011,2⁰ | I |
| ១២គ | សិលាចារឹក | K1011,3⁰ | I |
| ១២ឃ | សិលាចារឹក | K1011,4⁰ | I |
| ១២ង | ព្រះឥសូរនិងនាងឧមាលើព្រះគោ | 6 | I |
| ១២ច | ចម្លាក់ផ្កាឈូក | | I |
| ១២ឆ | រូបព្រះគោ | | I |
| ១៣ | ពើងមានសិលាចារឹកនិងបល្ល័ង្កឆ្លាក់ផ្ទាល់លើថ្មធម្មជាតិ | | I |
| ១៣ក | សិលាចារឹក | K1011,5⁰ | I |
| ១៤ | លិង្គរាយនៅបាតស្ទឹង | 7 | II |
| ១៥ | លិង្គជាក្រុម | | II |
| ១៦ | ចម្លាក់ក្រឡេតទាប | 8 | II |
| ១៦ក | ចម្លាក់ក្រឡេតទាប | | II |
| ១៦ខ | ចម្លាក់ក្រឡេតទាប | | II |
| ១៧ | ចម្លាក់ក្រឡេតទាប | | II |
| ១៨ | លិង្គរាយនៅបាតស្ទឹង | 9 | III |
| ១៩ | លិង្គជាក្រុម | 9 | III |
| ២០ | ព្រះនារាយណ៍ផ្ទំលើនាគ | | III |
| ២០ក | ព្រះនារាយណ៍ផ្ទំលើនាគ | | III |
| ២០ខ | ព្រះនារាយណ៍ផ្ទំលើនាគ | | III |
| ២០គ | ព្រះនារាយណ៍ផ្ទំលើនាគ | | III |
| ២១ | លិង្គទោល | | IV |

| | | | |
|---|---|---|---|
| ២២ | ព្រះនារាយណ៍ផ្ទំលើនាគ | 10 | IV |
| ២២ក | ព្រះនារាយណ៍ផ្ទំលើនាគ | 10 | IV |
| ២២ខ | ព្រះនារាយណ៍ផ្ទំលើនាគ | 10 | IV |
| ២៣ | ព្រះនារាយណ៍ផ្ទំលើនាគ | 10 | IV |
| ២៤ | ព្រះនារាយណ៍ផ្ទំលើនាគ | | IV |
| ២៥ | ចម្លាក់ផ្កាឈូក | | IV |
| ២៦ | សិលាចារឹកនៅដាច់តែឯង | K1015 | IV |
| ២៧ | សិលាចារឹកនៅដាច់តែឯង | | IV |
| ២៨ | ពើងមានបំណែកវត្ថុ* | | IV |
| ២៨ក | បំណែកលិង្គ | | IV |
| ២៨ខ | បំណែកខ្លួននាគ | | IV |
| ២៩ | លិង្គវាយនៅបាតស្ទឹង | | V |
| ៣០ | លិង្គបញ្ឈរ | | V |
| ៣១ | លិង្គជាក្រុម | | V |
| ៣២ | លិង្គជាក្រុម | | V |
| ៣៣ | លិង្គដែលមានទំហំធំ | 14 | V |
| ៣៤ | លិង្គទោល | | V |
| ៣៥ | ព្រះនារាយណ៍ផ្ទំលើនាគ | 12 | V |
| ៣៦ | ព្រះនារាយណ៍ផ្ទំលើនាគ | | V |
| ៣៧ | ព្រះនារាយណ៍ផ្ទំលើនាគ | | V |
| ៣៨ | ចម្លាក់រូបទេព | 13 | V |
| ៣៨ក | ព្រះនារាយណ៍ផ្ទំលើនាគ | 13 | V |
| ៣៨ខ | ព្រះនារាយណ៍ផ្ទំលើនាគ | 13 | V |
| ៣៨គ | ព្រះឥសូរនិងនាងឧមាលើព្រះគោ | 13 | V |
| ៣៩ | ចម្លាក់រូបទេព | 13 | V |
| ៣៩ក | ព្រះនារាយណ៍ផ្ទំលើនាគ | 13 | V |
| ៣៩ខ | ព្រះនារាយណ៍ផ្ទំលើនាគ | 13 | V |
| ៣៩គ | ព្រះឥសូរនិងនាងឧមាលើព្រះគោ | 13 | V |
| ៤០ | ព្រះព្រហ្ម | 15 | V |

* យើងពុំឃើញមានស្លាកស្នាមបុរាណដែលមានការពាក់ព័ន្ធផ្ទាល់នឹងពើងនេះទេ ថ្វីត្បិតតែសព្វថ្ងៃគេរក្សាទុកបំណែកបុរាណវត្ថុខ្លះនៅទីនោះ។ ប៉ុន្តែយោងតាមលំហធំទូលាយនៃពើងព្រមទាំងវត្ថុមានសិលាចារឹកពីរ នៅពុំឆ្ងាយទីនោះ យើងយល់ថាខ្មែរបុរាណប្រហែលជាប្រើប្រាស់ពើងនោះដែរ។



រូបលេខ១១. ចម្លាក់នៅបាតស្ទឹង (លេខជំរឿនថ្មី៨) ៖ អាងទឹកមានបល្ល័ង្កចំកណ្ដាល។ជុំវិញអាងមានលិង្គរាយចំនួន១៧១។ នៅជញ្ជាំងអាងមានចម្លាក់ព្រះនារាយណ៍ផ្ទុំលើនាគ២ផ្ទាំង (លេខ ៨កនិងលេខ៨១) តែពុំបានបង្ហាញនៅទីនេះទេ។



រូបលេខ១២. ចម្លាក់នៅបាតស្ទឹង (លេខជំរឿនថ្មី២០១) ៖ ព្រះនារាយណ៍ផ្ទុំលើនាគ មានកាន់ដំបងជាកេតនភណ្ឌ។ នាងលក្ស្មីអង្គុយរិតប្របាច់ព្រះបាទានៃព្រះអង្គ។ នៅចុងផ្ទាំងថ្មខាងជើង មានផ្កាឈូកពាទង។ ផ្នែកខាងលើសុទ្ធសឹងជារូបលិង្គចំនួនច្រើនលើសលុប ហើយដែលឆ្លាក់សម្រាប់មើលពីលើ។



រូបលេខ១៣. សិលាចារឹកនៅជាច់តែងង (លេខជំរឿនថ្មី២៧) ៖ អក្សរ៤បន្ទាត់ជាភាសាសំស្ក្រឹត, ពុំទាន់មានការបកប្រែនៅឡើយ។

## ឯកសារពិគ្រោះ

ចាយ រចនា, *បូជនីយដ្ឋានក្បាលស្ពាន*, និក្ខេបបទបញ្ចប់បរិញ្ញាប័ត្របុរាណវិទ្យា, ភ្នំពេញ, ២០០២។

អាជ្ញាធរអប្សរា, *បេតិកភណ្ឌក្បាលស្ពាន*, ២០០៣។

Boulbet, J. et Dagens, B., 1973, *Les sites archéologiques de la région du Phnom Kulen,* (*Arts Asiatiques*, XXVII).

Jacques, Cl., 1971, "Supplément au tome VIII des *Inscriptions du Cambodge*", *BEFEO*, LVIII : 177-195.

Jacques, Cl., 1999, "Les inscriptions du Phnom Kbal Spean", *BEFEO*, LXXXVI : 357-364.

Lunet de Lajonquière, E., 1902-1912, *Inventaire descriptif des monuments du Cambodge,* 3 vol., E. Leroux, Paris.

Parmentier, H., 1913, "Complément à l'inventaire descriptif des monuments du Cambodge", *BEFEO*, XIII (1) : 1-64.

Stern, Ph., 1938, "Mission au Cambodge. Recherches archéologiques sur le Phnom Kulèn (II) : Pr. Nak Ta, Krus Preah Aram Ron Cen, Pr. Damrei Krap", *BEFEO,* XXXVIII : 426 sqq.